ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៩៥ អយក.ប្រក

# ប្រកាស
# ស្ដីពី
# ការបណ្ដុះបណ្ដាលឯកទេសវិជ្ជាជីវៈនាយកសាលានៅវិទ្យាស្ថានជាតិអប់រំ
## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៣/០១២ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មមាត្រា២៨ នៃច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០០២ ស្ដីពីលក្ខណៈ វិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្ដីពីការបង្កើតនិងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សានិងសិក្សាឯកទេស



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

- បានឃើញអនុក្រឹត្យលេខ ១៥៣ អនក្រ. បក. ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤ ស្តីពីក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ. បក. ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៤ ស្តីពីការប្រែក្លាយមហាវិទ្យាល័យគរុកោសល្យទៅជាវិទ្យាស្ថានជាតិអប់រំ
- យោងតាមការចាំបាច់របស់ក្រសួងអប់រំ យុវជន និងកីឡា

**សម្រេច**

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១ .-**

ប្រកាសនេះ មានគោលបំណងកំណត់ អំពីការបណ្តុះបណ្តាលឯកទេសវិជ្ជាជីវៈនាយកសាលា នៅវិទ្យាស្ថានជាតិអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដើម្បីអភិវឌ្ឍសមត្ថភាពបុគ្គលិកអប់រំដែលចង់ក្លាយជានាយក នាយិកា នាយករង ឬនាយិការង ឱ្យស្របតាមស្តង់ដានាយកសាលារៀន។

**ប្រការ២ .-**

ប្រកាសនេះ មានគោលដៅកំណត់អំពី៖

- លក្ខខណ្ឌនៃការបណ្តុះបណ្តាល និងលក្ខខណ្ឌនៃការជ្រើសរើសនិស្សិតឱ្យចូលរៀនឯកទេសវិជ្ជាជីវៈនាយកសាលា
- លក្ខខណ្ឌនៃការបញ្ចប់ការសិក្សា និងទទួលសញ្ញាបត្រឯកទេសវិជ្ជាជីវៈនាយកសាលា
- បង្កើនសមត្ថភាពឯកទេសវិជ្ជាជីវៈនាយកសាលា ដល់បុគ្គលិកអប់រំដែលចង់ក្លាយជានាយក នាយិកា នាយករង ឬនាយិការង។

**ប្រការ៣ .-**

ប្រកាសនេះ មានវិសាលភាពអនុវត្តលើការបណ្តុះបណ្តាលបុគ្គលិកអប់រំ លើឯកទេសវិជ្ជាជីវៈនាយកសាលានៅមធ្យមសិក្សាទុតិយភូមិ នៃវិទ្យាស្ថានជាតិអប់រំ។

## ជំពូកទី២

## លក្ខខណ្ឌនៃការបណ្តុះបណ្តាល និងការជ្រើសរើសនិស្សិត

**ប្រការ៤ .-**

វិទ្យាស្ថានជាតិអប់រំ ត្រូវបណ្តុះបណ្តាលឯកទេសវិជ្ជាជីវៈនាយកសាលាក្នុងរយៈពេល១ឆ្នាំ តាមរូបភាពរដ្ឋ និងតាមរូបភាពបង់ថ្លៃសិក្សា ដែលមានសញ្ញាបត្រសមមូលនឹងបរិញ្ញាបត្រជាន់ខ្ពស់។

ការបណ្តុះបណ្តាលនេះ ត្រូវអនុវត្តតាមកម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់ សម្រាប់វគ្គឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ។

វិទ្យាស្ថានជាតិអប់រំ ត្រូវរៀបចំកម្មវិធីសិក្សាដែលមាន៥៨ ក្រេឌីត និងមានខ្លឹមសារសង្ខេប ដូចជា បំណិនត្រិះរិះពិចារណា និងនវានុវត្តន៍ ឧត្តមភាពបុគ្គល អធិការកិច្ចសាលារៀន ការចូលរួមរបស់ភាគី

ពាក់ព័ន្ធ ការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ ការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល ការគ្រប់គ្រងធនធាន ការលើកកម្ពស់ការបង្រៀននិងរៀន និងវិធីសាស្ត្រនៃការស្រាវជ្រាវក្នុងវិស័យអប់រំ ព្រមទាំងការសរសេរនិក្ខេបបទ ឬរបាយការណ៍ស្រាវជ្រាវ។

វិទ្យាស្ថានជាតិអប់រំ ត្រូវអភិវឌ្ឍកម្មវិធីសិក្សាសម្រាប់បណ្តុះបណ្តាលឯកទេសវិជ្ជាជីវៈនាយក ឱ្យស្របតាមការអភិវឌ្ឍរបស់ប្រទេសនិងពិភពលោក ដោយមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា។

**ប្រការ៥ .-**

វិទ្យាស្ថានជាតិអប់រំ ត្រូវជ្រើសរើសនិស្សិតឱ្យចូលរៀន ជ្រើសរើសគ្រូឧទ្ទេសមកបង្រៀន និងគ្រប់គ្រងការរៀន ការបង្រៀន ការប្រឡង ការវាយតម្លៃនិក្ខេបបទ ឬរបាយការណ៍ស្រាវជ្រាវ ការប្រគល់សញ្ញាបត្រ និងត្រូវធ្វើរបាយការណ៍រាល់សកម្មភាពសិក្សា និងការបណ្តុះបណ្តាលប្រចាំខែ ត្រីមាស និងឆមាសនីមួយៗ ជូនក្រសួងអប់រំ យុវជន និងកីឡា។

**ប្រការ៦ .-**

ការជ្រើសរើសនិស្សិតឱ្យចូលរៀន ត្រូវគោរពលក្ខខណ្ឌដូចខាងក្រោម៖

- បេក្ខជនទាំងពីរភេទ ត្រូវមានសញ្ញាបត្របរិញ្ញាបត្រ ឬសញ្ញាបត្រដែលមានតម្លៃស្មើ
- បេក្ខជនទាំងពីរភេទ ត្រូវឆ្លងកាត់ការប្រឡងជ្រើសរើស ឬដោយគណៈកម្មការជ្រើសរើស
- បេក្ខជនទាំងពីរភេទ ត្រូវគោរពតាមលក្ខខណ្ឌផ្សេងទៀតតាមការចាំបាច់។

វិទ្យាស្ថានជាតិអប់រំ ត្រូវរៀបចំសេចក្តីជូនដំណឹងសម្រាប់ជ្រើសរើស និងលក្ខខណ្ឌលម្អិតផ្សេងទៀត សម្រាប់ជ្រើសរើសនិស្សិតតាមឆ្នាំសិក្សានីមួយៗ។ ការជ្រើសរើសនេះត្រូវផ្តល់អាទិភាពដល់គ្រូបង្រៀនជ័យលាភីពានរង្វាន់សម្តេចតេជោសែន អធិការបឋមសិក្សាដែលមានស្រាប់ បុគ្គលិកអប់រំដែលមានអតីតភាពការងារ និងបុគ្គលិកអប់រំដែលមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ដែលបញ្ចប់ការសិក្សាដោយសរសេរនិក្ខេបបទ។

## ជំពូកទី៣
## លក្ខខណ្ឌនៃការបញ្ចប់ការសិក្សា និងការទទួលបានសញ្ញាបត្រ

**ប្រការ៧ .-**

និស្សិតដែលបានបំពេញគ្រប់លក្ខខណ្ឌនៃការបណ្តុះបណ្តាល ត្រូវទទួលបានសញ្ញាបត្រឯកទេសវិជ្ជាជីវៈនាយកសាលា មានតម្លៃសមមូលនឹងសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ដោយមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា។

**ប្រការ៨ .-**

និស្សិតដែលទទួលសញ្ញាបត្រឯកទេសវិជ្ជាជីវៈនាយក ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- បានរៀនចប់កម្មវិធីសិក្សា និងគ្រប់ក្រេឌីត
- បានប្រឡងបញ្ចប់គ្រប់មុខវិជ្ជា

- បានសរសេរ និងការពារនិក្ខេបបទ ឬរបាយការណ៍ស្រាវជ្រាវចប់ជាស្ថាពរ ដែលទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា។

វិទ្យាស្ថានជាតិអប់រំ ត្រូវរៀបចំបញ្ជីឈ្មោះនិស្សិត បញ្ចប់ការសិក្សាជាស្ថាពរ ដើម្បីសុំការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា។

ការចំណាយសម្រាប់ដំណើរការបណ្តុះបណ្តាលឯកទេសវិជ្ជាជីវៈនាយក ត្រូវប្រើប្រាស់ថវិការបស់ជាតិក្នុងគម្រោងរបស់ក្រសួងអប់រំ យុវជន និងកីឡា ថវិកាដៃគូអភិវឌ្ឍ និងថវិកាដែលបានមកពីសេវាបង់ថ្លៃសិក្សារបស់និស្សិតសិក្សាបង់ថ្លៃ។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**ប្រការ៩ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ១០ .-**

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានឧត្តមសិក្សា អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយ និងផែនការ អគ្គនាយកនៃអគ្គនាយកដ្ឋានយុវជន អគ្គនាយកនៃអគ្គនាយកដ្ឋានកីឡា អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកវិទ្យាស្ថានជាតិអប់រំ និងប្រធានគ្រប់អង្គភាពដែលពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៧ កើត ខែ មាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មករា ឆ្នាំ២០១៨

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យរដ្ឋមន្ត្រី

"ដើម្បីជ្រាប"

- គ្រប់អង្គភាពក្រោមឱវាទក្រសួង អ.យ.ក

"ដើម្បីជូនជ្រាប"

- ដូចប្រការ១០ "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ នា. នីតិកម្ម

**បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន**